ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងបរិស្ថាន
លេខ: ៥១០ ប្រ.ក.....ប.ស្ត

# ប្រកាស
# ស្តីពី
# ការរៀបចំបង្កើតសហគមន៍តំបន់ការពារធម្មជាតិ«ព្រៃឈើភ្លើង» នៃដែនជម្រកសត្វព្រៃគូលែន-ព្រហ្មទេព ស្ថិតក្នុងភូមិកោងយោង ឃុំយាង ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ

## រដ្ឋមន្ត្រីក្រសួងបរិស្ថាន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩១៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រិត្យលេខ នស/រកត/០៩១៣/៩០៣/ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រិត្យលេខ នស/រកត/០៤១៦/៣៦៨/ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការបញ្ចប់ និងតែងតាំងមុខងារ
- បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខនស/រកម/០២០៨/០០៧ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីតំបន់ការពារធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ ១៣៥អនក្រ.បក ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៦ របស់រាជរដ្ឋាភិបាលស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- បានឃើញលិខិតចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៥ ស្តីពីការស្នើសុំបង្កើតសហគមន៍តំបន់ការពារធម្មជាតិ «ព្រៃឈើភ្លើង»
- យោងតាមតម្រូវការចាំបាច់

## សម្រេច

**ប្រការ១.**_

ត្រូវបានទទួលស្គាល់សហគមន៍តំបន់ការពារធម្មជាតិ «ព្រៃឈើភ្លើង» នៃដែនជម្រកសត្វព្រៃគូលែន-ព្រហ្មទេព ស្ថិតក្នុងភូមិកោងយោង ឃុំយាង ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ។

អគារមរតកតេជោ ដីឡូលេខ503 ផ្លូវកៅស៊ូអមមាត់ទន្លេបាសាក់ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ភ្នំពេញ ទូរស័ព្ទ: ០២៣ ២១៣ ៩០៨, ០២៣ ២២០ ៣៦៩ ទូរសារ: ០២៣ ២១២ ៥៤០

**ប្រការ២.**_

សហគមន៍តំបន់ការពារធម្មជាតិ «ព្រៃឈើភ្លើង» នៃដែនជម្រកសត្វព្រៃគូលែន-ព្រហ្មទេព មានផ្ទៃដីទំហំ ២១៦២ហិកតា (ពីរពាន់មួយរយហុកសិបពីរហិកតា) ដូចមានផែនទីភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសនេះ និងមាននិយាមកា (Datum: WGS 1984) ដូចខាងក្រោម៖

| ID | ចំណុច | X | Y | ID | ចំណុច | X | Y |
|---|---|---|---|---|---|---|---|
| 1 | A | ៤៧២២៦៣ | ១៥៤៦៤៨៩ | 12 | L | ៤៦៤៩៨៩ | ១៥៤៥៥៩១ |
| 2 | B | ៤៧៣១៦១ | ១៥៤៥៩៩២ | 13 | M | ៤៦៤៧០៩ | ១៥៤៦១៦៦ |
| 3 | C | ៤៧៣១៦៦ | ១៥៤៥៨១៣ | 14 | N | ៤៦៤៥៦១ | ១៥៤៦៥៥៩ |
| 4 | D | ៤៧២៨០៦ | ១៥៤៥៧៧១ | 15 | O | ៤៦៤១៨១ | ១៥៤៦៥២៧ |
| 5 | E | ៤៧២១៣៩ | ១៥៤៤៨៤០ | 16 | P | ៤៦៤០៨១ | ១៥៤៧០២៤ |
| 6 | F | ៤៧១១១១ | ១៥៤៤៨៧៣ | 17 | Q | ៤៦៤៤៦១ | ១៥៤៧៧៣៣ |
| 7 | G | ៤៧០២៥៥ | ១៥៤៤៩១៤ | 18 | R | ៤៦៤១៥៦ | ១៥៤៨១៦០ |
| 8 | H | ៤៦៨៦១៣ | ១៥៤៤៨០៨ | 19 | S | ៤៦៤៥៦៩ | ១៥៤៨៣៣៨ |
| 9 | I | ៤៦៧១២៤ | ១៥៤៤០៨២ | 20 | T | ៤៦៦៨២១ | ១៥៤៧៧៦៤ |
| 10 | J | ៤៦៦២០១ | ១៥៤៤៦៣២ | 21 | U | ៤៦៩២៨៧ | ១៥៤៧១៣៦ |
| 11 | K | ៤៦៥៥១៧ | ១៥៤៤៦៩៦ | 22 | V | ៤៧១៦១១ | ១៥៤៦៥៤៣ |

**ប្រការ៣.**_

ការរៀបចំបង្កើតសហគមន៍តំបន់ការពារធម្មជាតិព្រៃឈើភ្លើង ក្នុងគោលបំណងបង្កើនការចូលរួមគ្រប់គ្រងប្រើប្រាស់ធនធានធម្មជាតិប្រកបដោយចីរភាព និងការរួមចំណែកលើកកម្ពស់ជីវភាពសហគមន៍មូលដ្ឋានស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល។

**ប្រការ៤.**_

សហគមន៍តំបន់ការពារធម្មជាតិ «ព្រៃឈើភ្លើង» នៃដែនជម្រកសត្វព្រៃគូលែន-ព្រហ្មទេព ត្រូវចុះកិច្ចព្រមព្រៀងជាមួយអគ្គនាយកដ្ឋានសហគមន៍មូលដ្ឋាន នៃក្រសួងបរិស្ថាន។ សហគមន៍តំបន់ការពារធម្មជាតិ «ព្រៃឈើភ្លើង» ត្រូវរៀបចំលក្ខន្តិកៈ និងផែនការគ្រប់គ្រងស្របតាមច្បាប់ស្តីពីតំបន់ការពារធម្មជាតិ។

**ប្រការ៥.**_

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៦.**_

អគ្គនាយកនៃអគ្គនាយកដ្ឋានសហគមន៍មូលដ្ឋាន អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលការពារនិងអភិរក្សធម្មជាតិ អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានគាំពារបរិស្ថាន អគ្គនាយកនៃអគ្គនាយកដ្ឋានចំណេះដឹងនិងព័ត៌មានបរិស្ថាន ខុទ្ទកាល័យរដ្ឋមន្ត្រី អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរបរិស្ថានខេត្តព្រះវិហារ នាយកដែនជម្រកសត្វព្រៃគូលែន-ព្រហ្មទេព និងសហគមន៍តំបន់ការពារធម្មជាតិ «ព្រៃឈើភ្លើង» ត្រូវអនុវត្តន៍ប្រកាសនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

<u>កន្លែងទទួល</u>
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- សាលាខេត្តព្រះវិហារ
- ដូចប្រការ៦ «ដើម្បីអនុវត្ត»
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ [illegible] ឆ្នាំ២០១៦

រដ្ឋមន្ត្រី

សាយ សំអាល់

# ផែនទី សហគមន៍តំបន់ការពារធម្មជាតិ ព្រៃឈើភ្លើង ស្ថិតក្នុងដែនជម្រកសត្វព្រៃ គូលែន-ព្រហ្មទេព
## ភូមិសាស្ត្រភូមិកោងយោង ឃុំយាង ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ

ឧបសម្ព័ន្ធ: ប្រកាសលេខ ៤១០ ប្រ.គស
ចុះថ្ងៃទី ០៩..... ខែ ធ្នូ........ ឆ្នាំ២០១៥
របស់ក្រសួងបរិស្ថាន




| Id | Name | X | Y |
|---|---|---|---|
| 1 | A | 472263 | 1546489 |
| 2 | B | 473161 | 1545992 |
| 3 | C | 473166 | 1545813 |
| 4 | D | 472806 | 1545771 |
| 5 | E | 472139 | 1544840 |
| 6 | F | 471111 | 1544873 |
| 7 | G | 470255 | 1544914 |
| 8 | H | 468613 | 1544808 |
| 9 | I | 467124 | 1544082 |
| 10 | J | 466201 | 1544632 |
| 11 | K | 465517 | 1544696 |
| 12 | L | 464989 | 1545591 |
| 13 | M | 464709 | 1546166 |
| 14 | N | 464561 | 1546559 |
| 15 | O | 464181 | 1546527 |
| 16 | P | 464081 | 1547024 |
| 17 | Q | 464461 | 1547733 |
| 18 | R | 464156 | 1548160 |
| 19 | S | 464569 | 1548338 |
| 20 | T | 466821 | 1547764 |
| 21 | U | 469287 | 1547136 |
| 22 | V | 471611 | 1546543 |

**កំណត់សំគាល់**

- ចំនុចនិយាមកា
- ផ្លូវជាតិ
- ផ្លូវលំ, ផ្លូវ តាមរទេះ
- ស្ទឹង, ទន្លេ, អូរ
- សហគមន៍តំបន់ការពារធម្មជាតិ
- ដែនជម្រកសត្វព្រៃគូលែន-ព្រហ្មទេព

